**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ៥២៩ អនក្រ.បក

**អនុក្រឹត្យ**
**ស្តីពី**

**ការកែសម្រួលមាត្រា ៨ និងមាត្រា ១០ នៃអនុក្រឹត្យ លេខ៦៨អនក្រ. ចុះថ្ងៃទី ២៥ ខែតុលា ឆ្នាំ ១៩៩៤ ស្តីពីលិខិតឆ្លងដែន នៃព្រះរាជាណាចក្រកម្ពុជា**

**រាជរដ្ឋាភិបាល**

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៦៨ អនក្រ ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីលិខិតឆ្លងដែន នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

**សម្រេច**

**មាត្រាមួយ.–**

មាត្រា៨និងមាត្រា១០នៃអនុក្រឹត្យលេខ៦៨អនក្រ ចុះថ្ងៃទី ២៥ ខែតុលា ឆ្នាំ១៩៩៤ស្តីពីលិខិតឆ្លងដែន នៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានកែសម្រួលដូចតទៅ៖

**មាត្រា ៩.-ថ្មី**

លិខិតឆ្លងដែនធម្មតាផ្តល់ជូនពលរដ្ឋខ្មែរ ទាំង២ភេទ សម្រាប់ធ្វើដំណើរទៅបរទេស។

ការផ្តល់លិខិតឆ្លងដែនដល់កុមារអាយុក្រោម១៨ឆ្នាំ ត្រូវមានសំណើ ឬការអនុញ្ញាតជាលាយល័ក្ខអក្សរពីឪពុក ម្តាយ ឬ អាណាព្យាបាល ដោយមានភ្ជាប់មកជាមួយ ឯកសារសម្គាល់គ្រួសារ និងសំបុត្រកំណើត។

**មាត្រា១០.-ថ្មី**

លិខិតឆ្លងដែន ធម្មតាមានសុពលភាពរយៈពេល ០៥ឆ្នាំ សម្រាប់កុមារ មានអាយុពី ០ឆ្នាំ ដល់ អាយុ៥ឆ្នាំ និងមានសុពលភាពរយៈពេល ១០ឆ្នាំ សម្រាប់អ្នកដែលមានអាយុពី ៦ឆ្នាំ ឡើង។

**មាត្រាពីរ.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយ នឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រាបី.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ខែ ធ្នូ ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេច អគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រាបី
- រាជកិច្ច
- ឯកសារកាលប្បវត្តិ